1/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 06 / 2011
ម៉ោង (Time/Heure) : 17:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (១)
Case File/Dossier N°. 002/19-09-2007-ECCC/SC(1)

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រីម ប្រធាន |
| | ចៅក្រម Motoo Noguchi |
| | ចៅក្រម ម៉ុង មុនីចរិយា |
| | ចៅក្រម Agniezska KLONOWIECKA-MILART |
| | ចៅក្រម ស៊ិន រិទ្ធ |
| | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ០៣ ខែ មិថុនា ឆ្នាំ ២០១១ |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ ដោយសារកង្វះឯករាជភាព

**សហព្រះរាជអាជ្ញា៖**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ៖**
អៀង ធីរិទ្ធ

**មេធាវីជនជាប់ចោទ៖**
ផាត់ ពៅស៊ាង
Diana ELLIS, QC

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួលសំណើ ដែលដាក់ដោយសហមេធាវីអន្តរជាតិការពារជនជាប់ចោទ អៀង ធីរិទ្ធ (“ជនជាប់ចោទ”) សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ដោយសារកង្វះឯករាជភាព (“សំណើ”)[១]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូងសុំឲ្យដោះលែងជាបន្ទាន់[២]។ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់[៣] ហើយនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើសំណើសុំរបស់ជនជាប់ចោទ[៤]។ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១ ជនជាប់ចោទបានចាប់ផ្តើមដំណើរការនីតិវិធីប្តឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយដាក់បណ្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (“បណ្តឹងសាទុក្ខភ្លាមៗ”)[៥]។ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ សំណើសុំរបស់ជនជាប់ចោទត្រូវបានជូនដំណឹងដល់ភាគីទាំងអស់។ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ អៀង សារី បានដាក់ញត្តិគាំទ្រសំណើនោះ (“ញត្តិ”)[៦]។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

---

[១] សំណើរបស់ អៀង ធីរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូលដោយសារការកង្វះឯករាជភាព, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ 1។

[២] សំណើបន្ទាន់ដើម្បីឲ្យដោះលែងអ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ E21។

[៣] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី – សំណើបន្ទាន់ដើម្បីឲ្យដោះលែង៖ នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១, ឯកសារ E1/1.1។

[៤] សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E50។

[៥] បណ្តឹងសាទុក្ខជំទាស់នឹង “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ” ដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលក្នុងនាមអ្នកស្រី អៀង ធីរិទ្ធ ជាដើមបណ្តឹងសាទុក្ខ, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១, ឯកសារ E50/2/1/1។ ជនជាប់ចោទបានដាក់សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ (ឯកសារ E50/2), ដែលមិនត្រូវឲ្យមាន តាមវិធាន១០៥(២) នៃវិធានផ្ទៃក្នុង, ថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១១។

[៦] ញត្តិរបស់លោក អៀង សារី គាំទ្រសំណើរបស់អ្នកស្រី អៀង ធីរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូល ដោយសារការខ្វះឯករាជភាព និងសំណើសុំឲ្យមានសវនាការសាធារណៈ, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ [illegible] ការបកប្រែជាភាសាខ្មែរ ត្រូវបានដាក់ នៅថ្ងៃទី៤ ខែ មេសា ឆ្នាំ ២០១១។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើនោះ ("សារណាតប")[៧] ហើយជនជាប់ចោទបានដាក់ការឆ្លើយតបទៅនឹងសារណាតបនោះនៅថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០១១ ("ការឆ្លើយតបទៅនឹងសារណាតប")[៨]។

## II. សារណា

២. នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ តុលាការកំពូលកម្ពុជាបានបដិសេធបណ្តឹងសាទុក្ខរបស់អ្នកនយោបាយរបស់គណៈបក្សប្រឆាំងគឺលោកស្រី មួរ សុខហួរ ជំទាស់ទៅនឹងសាលដីការបស់សាលាឧទ្ធរណ៍ ដែលសម្រេចតម្កល់ការវិនិច្ឆ័យទោសរបស់សាលាដំបូងពីបទបរិហារកេរ្តិ៍នាយករដ្ឋមន្ត្រី ហ៊ុន សែន[៩]។ ចៅក្រម សោម សិរិវឌ្ឍ គឺជាចៅក្រមម្នាក់ក្នុងចំណោមចៅក្រមប្រាំរូបនៅតុលាការកំពូលកម្ពុជា ដែលបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចទៅលើបណ្តឹងសាទុក្ខរបស់លោកស្រី មួរ សុខហួរ។ ជនជាប់ចោទយល់ឃើញថា "ការវិនិច្ឆ័យទោសលោកស្រី មួរ សុខហួរ នៅសាលាដំបូងត្រូវទទួលរងនូវការរិះគន់ពីបណ្តាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ថាគ្មានមូលដ្ឋានផ្លូវច្បាប់ និងត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UN OHCHR) និងសហភាពអន្តរសភា (IPU) ក៏បានសម្តែងនូវក្តីកង្វល់យ៉ាងខ្លាំងចំពោះការវិនិច្ឆ័យទោសនេះដែរ"[១០]។ ជនជាប់ចោទយល់ឃើញថា ការសម្រេចរបស់តុលាការកំពូលកម្ពុជាដែលបដិសេធបណ្តឹងសាទុក្ខរបស់លោកស្រី មួរ សុខហួរ "ត្រូវបានរិះគន់ដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជាច្រើន អង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប ដែលបានចេញសេចក្តីថ្លែងការណ៍ជាច្រើន ដោយធ្វើការកត់សម្គាល់ពីកង្វះខាតមូលហេតុសំអាងផ្លូវច្បាប់របស់តុលាការនៅទូទាំងដំណើរការច្បាប់"[១១]។ ដោយផ្អែកលើអង្គហេតុទាំងនេះ ជនជាប់ចោទយល់ឃើញដូចខាងក្រោម ៖

> ចៅក្រមម្នាក់ដែលត្រូវបានជ្រើសតាំងជាអង្គចៅក្រមហើយដែលបានវិនិច្ឆ័យទោស មួរ សុខហួរ ដោយផ្អែកលើមូលដ្ឋានបែបនេះ មិនអាចចាត់ទុកថាឯករាជ្យ និងអនាគតិទេ ហើយត្រូវតែបានដកចេញពីអង្គជំនុំ

---

[៧] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម សោម សិរិវឌ្ឍ ពីអង្គជំនុំជម្រះ តុលាការកំពូល ដោយសារការខ្វះឯករាជភាព, ថ្ងៃទី ២៤ ខែ មីនា , ឯកសារលេខ 1/2។

[៨] ការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម សោម សិរិវឌ្ឍ ពីអង្គជំនុំជម្រះតុលាការកំពូល ដោយសារការខ្វះឯករាជភាព, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ 1/3។

[៩] អគ្គព្រះរាជអាជ្ញា តទល់នឹង មួ សុខហួរ, តុលាការកំពូលកម្ពុជា, សំណុំរឿងព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ... សាលដីកាលេខ ៥៨ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ E63.1.1

[១០] សារណាបណ្តឹងសាទុក្ខ, កថាខណ្ឌ ៣ ។

[១១] សារណាបណ្តឹងសាទុក្ខ, កថាខណ្ឌ ២៤។



E.C.C.C * C.E.T.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

ជម្រះតុលាការកំពូលដែលត្រូវសម្រេចលើ [បណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ]។ តាមរយៈការពាក់ព័ន្ធរបស់គាត់ ក្នុងការតម្កល់សេចក្តីសម្រេចមួយ ដែលត្រូវបានពិចារណាដោយអ្នកអង្កេតការឯករាជ្យជាច្រើនថាគ្មានមូលដ្ឋានផ្អែកច្បាប់ និងត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ ចៅក្រម សោម សិរិវឌ្ឍ បានបង្ហាញយ៉ាងច្បាស់ពីការពាក់ព័ន្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលអាចប៉ះពាល់ដល់ឯករាជភាព និងអនាគតិរបស់គាត់នៅពេលពិចារណាសំណើលើកទី១។ ការពាក់ព័ន្ធលើកមុនជាអប្បបរមារបស់គាត់ក្នុងការតម្កល់សាលក្រមវិនិច្ឆ័យទោសដែលត្រូវបានជម្រុញដោយមូលហេតុនយោបាយ បង្កើតឱ្យមានភាពលម្អៀងពិតប្រាកដ[12]។

៣. នៅក្នុងញត្តិរបស់ អៀង សារី គាត់បានគាំទ្រសំណើនេះដោយផ្អែកលើអំណះអំណាងស្រដៀងគ្នាទៅនឹងអំណះអំណាងទាំងឡាយដែលបានលើកឡើងដោយជនជាប់ចោទ[១៣]។ សហព្រះរាជអាជ្ញាយល់ឃើញថាសំណើនេះគួរត្រូវបានបដិសេធចោល ដោយផ្អែកទៅលើហេតុផលដែលមានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីបណ្តឹងដិតចិត្តចៅក្រម ន័យ ថុល[១៤] និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងដិតចិត្តចៅក្រម និល ណុន[១៥] ដែលសំណើទាំងនេះពុំមានលក្ខណៈខុសគ្នាអ្វីនោះទេ[១៦]។

## III. សំអាងហេតុ

### ក. ភាពអាចទទួលយកបាន

៤. ពាក្យបណ្តឹងដិតចិត្តចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូល ត្រូវតែបំពេញនូវលក្ខខណ្ឌត្រួតដើម្បីឱ្យពាក្យបណ្តឹងនោះត្រូវបានទទួលយកជាផ្លូវការ។ ទីមួយ ពាក្យបណ្តឹងត្រូវ "បង្ហាញឱ្យបានច្បាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ" (វិធានផ្ទៃក្នុង ៣៤(៣))។ ទីពីរ ពាក្យបណ្តឹង "ត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលដែលភាគីបានដឹងអំពីមូលហេតុនោះ" (វិធានផ្ទៃក្នុង ៣៤(៣))។ ទីបី នៅពេលដែលបណ្តឹងពាក់ព័ន្ធនឹងបញ្ហាដែលកើតឡើងមុនពេលការដាក់បណ្តឹងសាទុក្ខភ្លាមៗ ឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ពាក្យបណ្តឹងនោះត្រូវតែដាក់នៅពេល

---

12 សារណាបណ្តឹងសាទុក្ខ, កថាខណ្ឌ ៤។

១៣ ញត្តិ កថាខណ្ឌ ២៧-៣៨។

១៤ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងដិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល, ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, ឯកសារ C11/29។

១៥ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១១, ឯកសារ E5/3។

១៦ សារណាតប កថាខណ្ឌ ៦-៩។

ចាប់ផ្ដើមនីតិវិធីបណ្ដឹងសាទុក្ខ។ នៅពេលដែលបណ្ដឹងពាក់ព័ន្ធនឹងបញ្ហាដែលកើតឡើង ក្នុងអំឡុងពេលនីតិវិធីបណ្ដឹងសាទុក្ខ ឬកាលណាភាគីមិនបានដឹងនៅមុនពេលការដាក់បណ្ដឹងសាទុក្ខភ្លាមៗ ឬបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ពាក្យបណ្ដឹងនោះត្រូវដាក់នៅមុនពេលសេចក្ដីសម្រេចចុងក្រោយ ឬសាលដីកាលើបណ្ដឹងសាទុក្ខនោះ (វិធានផ្ទៃក្នុង ៣៤(៤)(ឃ))។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខខណ្ឌទាំងបីនេះ មានលក្ខខណ្ឌទីបួនជាចាំបាច់មួយទៀត ពោលគឺ ត្រូវតែមានបណ្ដឹងសាទុក្ខភ្លាមៗដែលដាក់ដោយម្ចាស់បណ្ដឹង ដែលកំពុងរង់ចាំសេចក្ដីសម្រេចពីអង្គជំនុំជម្រះ នៅពេលដែលម្ចាស់បណ្ដឹងដាក់បណ្ដឹងជំទាស់ចៅក្រម លក្ខខណ្ឌទីបួន តម្រូវឱ្យម្ចាស់បណ្ដឹងមានផលប្រយោជន៍ផ្លូវច្បាប់ (មូលដ្ឋានសំខាន់ចាំបាច់នៃបណ្ដឹង) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែលអាចត្រូវបានទទួលរងផលប៉ះពាល់ ប្រសិនបើអង្គជំនុំជម្រះពុំបានពិចារណាលើអង្គសេចក្ដីនៃសំណើសុំជំទាស់។ លក្ខខណ្ឌទីបួនក៏រារាំងភាគីមិនឱ្យប៉ុនប៉ងដាក់សំណើសុំជំទាស់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ ពោលគឺតាមរយៈការដាក់បណ្ដឹងសាទុក្ខភ្លាមៗដែលបង្ហាញនូវលក្ខណៈមិនអាចទទួលយកបាននោះ។

៥. សំណើនេះ ទាក់ទិននឹងបញ្ហាដែលបានកើតឡើងមុនពេលដែលជនជាប់ចោទអាចដាក់បណ្ដឹងសាទុក្ខភ្លាមៗមកអង្គជំនុំជម្រះតុលាការកំពូល។ ជនជាប់ចោទបានដាក់សំណើរយៈពេល១១ថ្ងៃ បន្ទាប់ពីលោកស្រីបានដាក់បណ្ដឹងសាទុក្ខភ្លាមៗរបស់លោកស្រី។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើនេះត្រូវបានដាក់ "នៅពេលចាប់ផ្ដើមនីតិវិធីបណ្ដឹងសាទុក្ខ" ស្របតាមវិធានផ្ទៃក្នុង ៣៤(៤)(ឃ)។ សំណើនេះក៏បំពេញនូវលក្ខខណ្ឌដទៃទៀតនៃភាពអាចទទួលយកបានជាផ្លូវការផងដែរ។

៦. អៀង សារី យល់ឃើញថា ញត្តិរបស់គាត់គឺអាចទទួលយកបាន "ដោយហេតុថា ក្រុមមេធាវីការពារក្ដីមានបណ្ដឹងសាទុក្ខចំនួនពីរដែលបច្ចុប្បន្នកំពុងរង់ចាំសេចក្ដីសម្រេចពីអង្គជំនុំជម្រះ"[១៧]។ នៅថ្ងៃទី០២ និងទី០៩ ខែ មីនា ឆ្នាំ ២០១១ អៀង សារី បានដាក់សេចក្ដីជូនដំណឹងចំនួនពីរអំពីបណ្ដឹងសាទុក្ខភ្លាមៗមកអង្គជំនុំជម្រះតុលាការកំពូល[១៨]។ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ អៀង សារី បានដាក់ញត្តិគាំទ្រសំណើនេះ។ នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សេចក្ដីជូនដំណឹងពីរអំពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ អៀង សារី មិនអាចទទួលយកបានឡើយ[១៩]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ញត្តិនេះបំពេញនូវលក្ខខណ្ឌទីបួនអំពីភាពអាចទទួលយកបានជាផ្លូវការ

---

[១៧] ញត្តិ កថាខណ្ឌ ១។

[១៨] ឯកសារ E9/7/1/1 និង E51/6/1។

[១៩] សេចក្ដីសម្រេចលើសេចក្ដីជូនដំណឹងពីរនៃបណ្ដឹងសាទុក្ខដែលដាក់ដោយ អៀង សារី, សំណុំរឿងលេខ 002/19-09-2007-អវតក/អជសដ/អជតក (០៣ និង ០៥), ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ២ ឯកសារ E9/7/1/1/1/4។

ដូចដែលបានបញ្ជាក់នៅខាងលើរួចហើយ ពីព្រោះ អៀង សារី មានការជូនដំណឹងពីរអំពីបណ្តឹងសាទុក្ខ ភ្លាមៗដែលរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះ នៅពេលដែលគាត់បានដាក់ញត្តិរបស់គាត់។

**ខ. សំណើសុំឱ្យមានសវនាការដេញដោលដោយផ្ទាល់មាត់ជាសាធារណៈ**

៧. ជនជាប់ចោទបានស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល បើកសវនាការដេញដោលដោយផ្ទាល់មាត់ជាសាធារណៈមួយ ពីព្រោះវានឹង "ផ្តល់ឱ្យភាគីនូវឱកាសដើម្បីឆ្លើយតបចំពោះអង្គហេតុដែលបានចោទប្រកាន់នៅក្នុងសំណើនេះ និងច្បាប់ដែលយកមកអនុវត្តក្នុងលក្ខណៈមួយលម្អិត" និង "វាមានលក្ខណៈសំខាន់ណាស់ដែលថា សំណើសុំជំទាស់ប្រឆាំងនឹងចៅក្រមត្រូវតែបានដោះស្រាយប្រកបដោយតម្លាភាពបំផុតតាមដែលអាចធ្វើបាន ដើម្បីអនុញ្ញាតឱ្យសាធារណជនទទួលបាននូវការយល់ដឹងឱ្យបានពេញលេញពីដំណើរការនីតិវិធី"[២០]។ អៀង សារី ក៏បានស្នើឱ្យមានសវនាការជាសាធារណៈដែលជាមធ្យោបាយមួយបើកឱ្យមានការស៊ើបសួរបន្ថែម នៅក្នុងការចោទប្រកាន់នានាអំពីភាពលម្អៀងប្រឆាំងនឹងចៅក្រម សោម សិរិវឌ្ឍ[២១]។ សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះ បដិសេធសំណើសុំឱ្យមានសវនាការជាសាធារណៈរបស់ជនជាប់ចោទ[២២]។

៨. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិធានផ្ទៃក្នុងពុំតម្រូវឱ្យមាន ឬបញ្ជាក់អំពីសិទ្ធិជាអាទិភាពដែលថាត្រូវតែមានសវនាការជាសាធារណៈ ដើម្បីពិចារណាអំពីបណ្តឹងជំទាស់នោះឡើយ[២៣]។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា "មិនចាំបាច់ស្តាប់ភាគី ឬចៅក្រមពាក់ព័ន្ធទេ"[២៤]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងដែលថា "តុលាការអន្តរជាតិផ្សេងទៀតតែងតែសម្រេចលើបណ្តឹងជំទាស់នេះ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ"[២៥]។

---

[២០] សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៤៨-៤៩។

[២១] ញត្តិ កថាខណ្ឌ ៣៨។

[២២] សារណាតប កថាខណ្ឌ ៩។

[២៣] វិធាន១០៩ (១) នៃវិធានផ្ទៃក្នុង។

[២៤] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៥៦១។

[២៥] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne និង ចៅក្រម ធូ មណី, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៨, ឯកសារលេខ 55/4 ("សេចក្តីសម្រេចលើញត្តិសុំជំទាស់ចៅក្រម អ.ជ.ស.ដ ទាំងអស់"); សេចក្តីសម្រេចរបស់អ.ប.ជទាក់ទងនឹងចៅក្រម ណិល ណុន, កថាខណ្ឌ ៨។ សេចក្តីសម្រេច អ.ជ.ស.ដ ទាក់ទងនឹងចៅក្រម និល ណុន, កថាខណ្ឌ ៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចលើញត្តិរបស់ Joseph Nzirorera សុំជំទាស់ចៅក្រម Byron, Kam និង Joensen, ICTR Bureau (ICTR-98-44-T), ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brdanin និង Talic,*



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

បន្ទាប់ពីបានពិនិត្យសំណើ ញត្តិ និងសារណាតបរួចមក អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការផ្តល់ឱកាសឱ្យជនជាប់ចោទដាក់ការឆ្លើយតបទៅនឹងសារណាតបជាលាយលក្ខណ៍អក្សរ គឺមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ឱ្យអង្គជំនុំជម្រះស្តាប់ទឡ្ហីករណ៍ពេញលេញរបស់ភាគីស្តីពីសំណើសុំនេះបានយ៉ាងត្រឹមត្រូវហើយ។ ពុំចាំបាច់មានការស៊ើបសួរទៅលើសំណើនេះបន្ថែមទៀតទៅលើសារណាជាលាយលក្ខណ៍អក្សរទាំងអស់នេះទេ។ ដើម្បីផលប្រយោជន៍នៃតម្លាភាព អង្គជំនុំជម្រះតុលាការកំពូលនឹងចាត់ប្រភេទឯកសារជាថ្មី ចំពោះសំណើ ញត្តិ សារណាតប និងការឆ្លើយតបទៅនឹងសារណាតប ជាប្រភេទឯកសារសាធារណៈ ក្នុងពេលវេលាសមស្រប។ សំណើរបស់ជនជាប់ចោទសុំឱ្យមានសវនាការ ត្រូវបដិសេធចោល។

## គ. ច្បាប់ជាធរមាន

៩. វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៧ ) ចែងដូចខាងក្រោម ៖

**វិធាន ៣៤: ការដកខ្លួន និងបណ្តឹងជំទាស់ចៅក្រម**

២. ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង។

៣. ភាគីដែលធ្វើបណ្តឹងជំទាស់ ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ។ ពាក្យបណ្តឹងត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ។

៤. ពាក្យបណ្តឹងជំទាស់ដែលអាចទទួលយកបានត្រូវតែធ្វើឡើងដើម្បី ៖

...

ឃ-ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងមុនពេលធ្វើបណ្តឹងសាទុក្ខ នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ ឬ ពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលនីតិវិធីបណ្តឹងសាទុក្ខ ឬ បញ្ហាដែលភាគីមិនបានដឹងនៅមុនពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខនោះ។

---

សេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ Momir Talic សុំប្តឹងជំទាស់ និងដកចៅក្រមមួយរូប (IT-99-36-PT) ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០០។

៥. ពាក្យបណ្តឹងជិតចិត្ត [ប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះតុលាការកំពូល]... ត្រូវដាក់ជូនទៅអង្គជំនុំជម្រះណាមួយ ដែលចៅក្រមនោះស្ថិតនៅ។ ចៅក្រមដែលកំពុងមានបញ្ហា អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជិតចិត្ត។ ប៉ុន្តែចៅក្រមនោះអាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន នៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី។

១០. អង្គជំនុំជម្រះតុលាការកំពូលអនុម័តក្របខណ្ឌច្បាប់ដូចខាងក្រោមនេះ ដើម្បីធ្វើការសម្រេចទៅលើបណ្តឹងជិតចិត្ត ដូចដែលបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង៖

វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា៖ "ភាគីអាចធ្វើបណ្តឹងជិតចិត្តចំពោះចៅក្រម ក្នុងករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលម្អៀង"។ អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បណ្តឹងទាំងនេះ "ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុខនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ"។

យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងតុលាការអន្តរជាតិផ្សេងទៀត បានសម្រេចដោយមានភាពស៊ីសង្វាក់គ្នាថា លក្ខណៈវិនិច្ឆ័យនៃអនាគតិត្រូវបានរំលោភ មិនមែនចាំបាច់តែចៅក្រមនោះមានភាពលម្អៀងជាក់ស្តែងនោះទេ គឺគ្រាន់តែស្តែងចេញឲ្យឃើញអំពីភាពលម្អៀងក៏បានដែរ។ ការស្តែងចេញឲ្យឃើញនូវភាពលម្អៀងរួមមាន (ក) ចៅក្រមរូបនោះគឺជាភាគីណាមួយក្នុងរឿងក្តី ឬមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុចំពោះលទ្ធផលនៃរឿងក្តី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឲ្យកើតចេញនូវបុព្វហេតុអ្វីមួយផ្សេងទៀតដែលចៅក្រមរូបនោះមានការពាក់ព័ន្ធឬ (ខ) កាលៈទេសៈទាំងនោះដែលធ្វើឲ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង។

អ្នកសង្កេតការណ៍មិនលម្អៀង ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យនេះត្រូវតែជា "បុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានា ដែលចៅក្រមត្រូវប្រកាន់យកឲ្យបានខ្ជាប់ខ្ជួន"។ ដូចដែលបានកត់សម្គាល់នៅក្នុងយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក ថា ចំណុចចាប់ផ្តើមនៃការកំណត់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្មតជាមុនសិនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម ដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ។ ភាគីដែលប្តឹងជិតចិត្តមានបន្ទុកត្រូវបង្ហាញផ្ទុយពីការសន្មតទុកជាមុនបែបនេះ ដែលជាលក្ខខណ្ឌកម្រិតខ្ពស់តម្រូវឲ្យភាគីដាក់បណ្តឹង[illegible]

[២៦] សេចក្តីសម្រេចលើញត្តិសុំជិតចិត្តចៅក្រម អ.ជ.ស.ដ ទាំងអស់, កថាខណ្ឌ ១០-១២។

## ឃ. ផ្នែកអង្គសេចក្តីនៃសំណើ

១១. ទឡ្ហីករណ៍ដ៏សំខាន់នៃសំណើនេះគឺថា ចៅក្រម សោម សិរិវឌ្ឍ គួរតែត្រូវបានដកចេញពីអង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក ក្នុងសំណុំរឿង ០០២ ពីព្រោះគាត់បានចូលរួមក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូលកម្ពុជា ដែលបានបដិសេធបណ្តឹងសាទុក្ខប្រឆាំងនឹងការវិនិច្ឆ័យទោសផ្នែកព្រហ្មទណ្ឌ ដែលត្រូវបានរិះគន់យ៉ាងច្រើនថា ត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ។ ទឡ្ហីករណ៍នេះពុំមានអង្គសេចក្តីឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា សំណើនេះ មិនបានសំដៅទៅលើពាក្យសម្តី ឬសកម្មភាពដែលអាចកំណត់បានរបស់ចៅក្រម សោម សិរិវឌ្ឍ ឡើយ ប៉ុន្តែផ្ទុយទៅវិញសំដៅទៅលើតុលាការកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានចូលរួមនៅក្នុងសំណុំរឿង *អគ្គព្រះរាជអាជ្ញា ទល់នឹង លោកស្រី មូរ សុខហួរ*[២៧]។ ទោះបីជាសំណើនេះសំដៅទៅលើចៅក្រម សោម សិរិវឌ្ឍ ក៏ដោយ ក៏វាមិនអាចកំណត់នូវយោបល់ផ្ទាល់ខ្លួនរបស់គាត់ទៅលើបណ្តឹងសាទុក្ខរបស់លោកស្រី មូរ សុខហួរ បានឡើយ ពីព្រោះសេចក្តីសម្រេចរបស់តុលាការកំពូលកម្ពុជាត្រូវធ្វើឡើងដោយមតិភាគច្រើន ច្បាប់កម្ពុជាពុំបានចែងឱ្យមានការផ្សព្វផ្សាយយោបល់ស្រប ឬយោបល់ជំទាស់ដាច់ដោយឡែកឡើយ ហើយដំណើរការនៃការពិភាក្សា និងចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់[២៨]។

១២. នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើនដែរ ចៅក្រមពេញសិទ្ធិមានសមត្ថភាពតិចតួចណាស់ក្នុងការជ្រើសរើសយករឿងក្តី ឬដកខ្លួនចេញពីរឿងក្តី។ នៅក្នុងប្រទេសកម្ពុជា ការបែងចែករឿងក្តីទៅឱ្យចៅក្រមត្រូវបានកំណត់ទុកជាមុនជារៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ[២៩]។ ការផ្លាស់ប្តូរចំពោះការបែងចែកនេះអាចធ្វើទៅបាន តែក្នុងកាលៈទេសៈកំណត់តិចតួចប៉ុណ្ណោះ ហើយត្រូវតែអនុម័តដោយដីកាសម្រេចរបស់ប្រធានតុលាការ[៣០]។ ចៅក្រម សោម សិរិវឌ្ឍ មិនអាចដកខ្លួនដោយឯកតោភាគីចេញពីរឿងក្តីរបស់អគ្គព្រះរាជអាជ្ញា ទល់នឹង លោកស្រី មូរ សុខហួរ បានឡើយ។ ការដកខ្លួន

---

[២៧] សារណាតប កថាខណ្ឌ ៧។

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៤-២៥, ដូចដែលត្រូវបានបកស្រាយឡើងវិញនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចៅក្រម យូរ ឧត្តរា ជើងទំព័រ ២៩។

[២៩] ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៦(១)-(២)។

[៣០] ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៦(៣) ("ការបែងចែករឿងក្តីនៅតុលាការ[illegible]ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈដែលត្រូវបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ មិន[illegible]ឡើង លើកលែងតែក្នុងករណីដែលចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីដែលចៅក្រមត្រូវ[illegible]ករណីដែលចៅក្រមបន្តមានធុរៈ ដោយសារហេតុផលដូចជាត្រូវឈប់សម្រាកក្នុងរយៈពេលវែង ជា[illegible]ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានតុលាការ")។

00702252



ដោយខ្លួនឯងរបស់ចៅក្រម ត្រូវបានអនុញ្ញាតក្រោមច្បាប់កម្ពុជាក្នុងរឿងក្តីព្រហ្មទណ្ឌ តែនៅពេលដែលប្រធានតុលាការ "យល់ឃើញថាមូលហេតុ [ចំពោះការដកខ្លួនដោយខ្លួនឯង] មានលក្ខណៈត្រឹមត្រូវ" ប៉ុណ្ណោះ[៣១]។

១៣. លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលរំឭកដល់ជនជាប់ចោទថា សំណើសុំជិតចិត្ត "ផ្អែកលើការចោទប្រកាន់នៃការប្រព្រឹត្តខុសឆ្គងក្នុងរឿងក្តីផ្សេង នឹងមិនទទួលជោគជ័យទេ លើកលែងតែមានភស្តុតាងបង្ហាញថា កំហុសនោះនឹងរារាំងមិនឱ្យចៅក្រមរូបនោះអនុវត្តបាននូវគំនិតអនាគតិ និងភាពមិនបុរេវិនិច្ឆ័យ" នៅក្នុងរឿងក្តីដែលកំពុងចាត់ការនៅអ.វ.ត.ក[៣២]។ ជនជាប់ចោទមិនបានផ្តល់នូវភស្តុតាងណាមួយបញ្ជាក់ថា ចៅក្រម សោម សិរិវឌ្ឍ អាចមិនមានឯករាជភាពឡើយ ទាក់ទិននឹងសំណុំរឿង ០០២ នៅ អ.វ.ត.ក ដោយសារតែការចូលរួមរបស់គាត់នៅក្នុងតុលាការកំពូលកម្ពុជា នៅក្នុងរឿងក្តី*អគ្គព្រះរាជអាជ្ញា ទល់នឹង លោកស្រី មូរ សុខហួរ*។ ជនជាប់ចោទផ្អែកទៅលើសេចក្តីអត្ថាធិប្បាយរបស់អ្នកសង្កេតការណ៍ដែលជាតតិយជន[៣៣] ដែលចង្អុលបង្ហាញថា រឿងក្តីអគ្គព្រះរាជអាជ្ញា ទល់នឹង លោកស្រី មូរ សុខហួរ

[៣១] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា, មាត្រា ៥៥៥។ *សូមមើលផងដែរ* ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៩ ("ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ឬកថាខណ្ឌទី១ នៃមាត្រា ២៨ (បណ្តឹងជិតចិត្តចៅក្រម) នៃក្រមនេះ ចៅក្រមអាចដកខ្លួនបាន ដោយទទួលការអនុញ្ញាតពីប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម")។

[៣២] សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងចៅក្រម និល ណុន កថាខណ្ឌ ៧, ៨។

[៣៣] អត្ថបទរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) មានចំណងជើងថា៖ 'Cambodia: Drop Charges Against Opposition MP and Her Lawyer' ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩។ អត្ថបទរបស់ Seth Mydans មានចំណងជើងថា៖ 'Cambodia Court Cases Mount Against Opposition' ក្នុងសារព័ត៌មាន *The New York Times* ចេញផ្សាយថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩។ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (LICADHO), 'សេចក្តីប្រកាសព័ត៌មាន៖ សាលក្រម មូរ សុខហួរ៖ Another Blow to Cambodian Democracy' ចេញផ្សាយថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), 'សេចក្តីប្រកាសព័ត៌មាន៖ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩ - Another Dark Day for Justice and Democracy in Cambodia', ចេញផ្សាយថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UN OHCHR) , 'Cambodian court case shows erosion of fundamental freedoms' ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៩។ អត្ថបទរបស់ UN OHCHR Cambodia, មានចំណងជើងថា៖ 'Statement on the compatibility of recent defamation and disinformation

គឺជាការជំនុំជម្រះក្តីគ្រាន់តែជាការរៀបចំឡើងដោយមូលហេតុនយោបាយតែប៉ុណ្ណោះ។ មានតែសេចក្តីអត្ថាធិប្បាយមួយប៉ុណ្ណោះក្នុងចំណោមសេចក្តីអត្ថាធិប្បាយទាំងអស់ ដែលសំដៅចំទៅលើឈ្មោះចៅក្រម សោម សិរិវឌ្ឍ ក៏ប៉ុន្តែការបង្ហាញតែប៉ុណ្ណោះមិនមានយុត្តិកម្មសម្រាប់ឱ្យតតិយជនមានការបារម្ភថា ចៅក្រម សោម សិរិវឌ្ឍ មិនអាចធ្វើជាចៅក្រមនៅ អ.វ.ត.ក បាននោះទេ[៣៤]។

១៤. យោងទៅលើហេតុផលខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងនៅក្នុងសំណើ ការឆ្លើយតបទៅនឹងសារណាតប និងញត្តិ នឹងមិនធ្វើឱ្យអ្នកសង្កេតការណ៍សត្យានុម័ត ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថា មានភាពលម្អៀងពីសំណាក់ចៅក្រម សោម សិរិវឌ្ឍ ទាក់ទិននឹងសំណុំរឿង០០២ នៅ អ.វ.ត.ក ឡើយ។ ដូច្នេះ សំណើ និងញត្តិ ត្រូវបដិសេធចោល។

---

verdicts' ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៩។ IPU, សំណុំរឿងលេខ CMBD/47 - មូរ សុខហួរ, សេចក្តីសម្រេចចិត្តដែលត្រូវបានអនុម័តដោយ IPU Governing Council នៅក្នុងសម័យប្រជុំលើកទី ១៨៥ របស់ខ្លួន ហ្សឺណែវ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៩។ IPU, សំណុំរឿងលេខ CMBD/47- មូរ សុខហួរ, សេចក្តីសម្រេចចិត្តដែលត្រូវបានអនុម័តជាអនាមិកដោយ IPU Governing Council នៅក្នុងសម័យប្រជុំលើកទី ១៨៥ របស់ខ្លួន, បាងកក ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០ និង IPU, Committee on the Human Rights of Parliamentarians, សំណុំរឿងលេខ CMBD/47 - មូរ សុខហួរ- កម្ពុជា សេចក្តីសម្រេចដែលត្រូវបានអនុម័តដោយគណៈកម្មាធិការនៅសម័យប្រជុំលើកទី ១៣០ របស់ខ្លួន ហ្សឺណែវ ថ្ងៃទី១២-១៥ ខែកក្កដា ឆ្នាំ២០១០។ ការវិភាគផ្នែកច្បាប់នៃសំណុំរឿងរបស់ប្រទេសកម្ពុជា តទល់នឹង មូរ សុខហួរ, CCHR ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ៥-៧។ សេចក្តីប្រកាសព័ត៌មានអង្គការសហប្រជាជាតិមានចំណងជើងថា៖ 'United Nations Expert Concerned at Restrictions on Freedom of Lawyers to Represent Their Clients in Cambodia', ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩។ អត្ថបទរបស់ CCHR មានចំណងជើងថា៖ 'Analysis of the Fairness of the Judicial Process Resulting in the Conviction of Elected Representative Mu Sochua' ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០។ អត្ថបទរបស់សភាអឺរ៉ុប មានចំណងជើងថា៖ 'Resolution on Cambodia, in particular the case of Sam Rainsy' ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០។ IPU, Committee on the Human Rights of Parliamentarians សំណុំរឿងលេខ *CMBD/47* - មូរ សុខហួរ កម្ពុជា, សេចក្តីសម្រេចដែលត្រូវបានអនុម័តដោយគណៈកម្មាធិការនៅសម័យប្រជុំលើកទី ១៣០ របស់ខ្លួន, ហ្សឺណែវ, ថ្ងៃទី ១២-១៥ កក្កដា ឆ្នាំ ២០១០។ មហាសន្និបាត អ.ស.ប, ក្រុមប្រឹក្សាសិទ្ធិមនុស្ស, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ដោយ Surya P. Subedi, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ អ.ស.ប A/HRC/15/46 កថាខណ្ឌ ៤៣។

[៣៤] អត្ថបទរបស់ CCHR មានចំណងជើងថា៖ 'Analysis of the Fairness of the Judicial Process Resulting in the Conviction of Elected Representative Mu Sochua' ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ 20 ឯកសារ E63.1.11 ។

## IV. ផ្នែកសម្រេចសេចក្តី

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**បដិសេធ** សំណើសុំរបស់ អៀង ធីរិទ្ធ និងញត្តិរបស់ អៀង សារី និង

**បដិសេធ** សំណើសុំឱ្យមានសវនាការដេញដោលដោយផ្ទាល់មាត់ជាសាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**